# មានកង្វល់អំពីការលូតលាស់ឬ?
# វិធីដើម្បីទទួលបានជំនួយសម្រាប់កូនរបស់អ្នក



Help Me Grow LA

ការពិភាក្សាជាមួយនឹងគ្រូពេទ្យគឺជាជំហានដំបូងឆ្ពោះទៅកាន់ការទទួលបានជំនួយសម្រាប់កូនរបស់អ្នក ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការលូតលាស់របស់គាត់ (របៀបដែលកូនរបស់អ្នកលេង រៀន និយាយ ធ្វើសកម្មភាព ឬធ្វើចលនា)។ សូមកុំរង់ចាំ។ ការធ្វើសកម្មភាពបានឆាប់រហ័ស អាចធ្វើឱ្យមានប្រយោជន៍យ៉ាងពិតប្រាកដ!

## 1 ធ្វើការណាត់ជួបជាមួយនឹងគ្រូពេទ្យរបស់កូនអ្នក

- នៅពេលដែលអ្នកកំណត់ពេលណាត់ជួប សូមប្រាប់ទៅដល់បុគ្គលិករបស់គ្រូពេទ្យថាអ្នកមានការព្រួយបារម្ភអំពីការលូតលាស់របស់កូនអ្នក ដែលអ្នកចង់ពិភាក្សាជាមួយនឹងគ្រូពេទ្យ។

## 2 បំពេញបញ្ជីត្រួតពិនិត្យព្រឹត្តការណ៍សំខាន់ៗ

- មុនពេលការណាត់ជួប សូមបំពេញបញ្ជីត្រួតពិនិត្យព្រឹត្តការណ៍សំខាន់ៗដោយទាញយក កម្មវិធីទូរស័ព្ទឈ្មោះ *Milestone Tracker* របស់មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) ដោយមិនគិតថ្លៃពី App Store ឬ Google
- សរសេរសំណួរ និងកង្វល់ទាំងឡាយរបស់អ្នក ហើយនាំយកសំណួរទាំងនេះទៅជាមួយនឹងអ្នកសម្រាប់ការណាត់ជួបជាមួយនឹងគ្រូពេទ្យ។

## 3 ក្នុងអំឡុងពេលការណាត់ជួបជាមួយនឹងគ្រូពេទ្យ

- បង្ហាញបញ្ជីត្រួតពិនិត្យព្រឹត្តការណ៍សំខាន់ៗដែលបានបំពេញរួចនោះទៅកាន់គ្រូពេទ្យ
  - ប្រសិនបើកូនរបស់អ្នកបានខកខានចំពោះព្រឹត្តិការណ៍សំខាន់ៗនានា សូមរៀបរាប់អំពីព្រឹត្តការណ៍សំខាន់ៗទាំងនោះ និងពិភាក្សាអំពីកង្វល់ផ្សេងទៀតដែលអ្នកមាន។
  - ប្រសិនបើកូនរបស់អ្នកមិនបានខកខានចំពោះព្រឹត្តការណ៍សំខាន់ៗទេនោះ ប៉ុន្តែអ្នកនៅតែមានកង្វល់ សូមប្រាប់គ្រូពេទ្យអំពីកង្វល់ទាំងនោះ។
- ស្នើសុំឱ្យមានការត្រួតពិនិត្យទៅលើការលូតលាស់សម្រាប់កូនរបស់អ្នក ពីគ្រូពេទ្យ
  - មានការណែនាំឱ្យមានការត្រួតពិនិត្យទៅលើការលូតលាស់ (developmental screening) នៅពេលណាមួយដែលមានកង្វល់។ ការត្រួតពិនិត្យនេះផ្តល់ព័ត៌មានបន្ថែមជូនទៅគ្រូពេទ្យ ដើម្បីស្វែងរករបៀបល្អបំផុតក្នុងការជួយដល់កូនរបស់អ្នក។
  - សម្រាប់ព័ត៌មានបន្ថែមអំពីការត្រួតពិនិត្យទៅលើការលូតលាស់ សូមចូលទៅកាន់គេហទំព័រ www.cdc.gov/DevScreening។
- សាកសួរទៅកាន់គ្រូពេទ្យថាតើកូនរបស់អ្នកត្រូវការឱ្យមានការវាយតម្លៃផ្នែកលូតលាស់បន្ថែមទៀតឬទេ
  - ប្រសិនបើកូនរបស់អ្នកត្រូវការ សូមស្នើសុំការបញ្ជូនឈ្មោះ និងហៅទូរស័ព្ទទៅកាន់ទីនោះភ្លាមៗ។ ប្រសិនបើអ្នកមានការពិបាកក្នុងការទទួលបានការណាត់ជួប សូមប្រាប់ទៅដល់គ្រូពេទ្យ។

## 4 ធ្វើឱ្យប្រាកដថាអ្នកយល់អំពីអ្វីដែលគ្រូពេទ្យប្រាប់អ្នក និងអ្វីដែលត្រូវធ្វើបន្ទាប់

- មុនពេលអ្នកចាកចេញពីការណាត់ជួបនោះ សូមពិនិត្យមើលកំណត់ត្រាដែលអ្នកបានសរសេរ និងធ្វើឱ្យប្រាកដថាបានទទួលចម្លើយសម្រាប់គ្រប់សំណួរទាំងអស់របស់អ្នក។
- ប្រសិនបើអ្នកមិនយល់អំពីអ្វីមួយ សូមស្នើសុំឱ្យគ្រូពេទ្យពន្យល់ចំណុចនោះម្តងទៀត ឬពន្យល់តាមវិធីផ្សេងមួយទៀត។
- នៅពេលដែលអ្នកទៅដល់ផ្ទះ សូមពិនិត្យមើលកំណត់ត្រារបស់អ្នក ហើយអនុវត្តតាមជំហានទាំងឡាយដែលគ្រូពេទ្យបានផ្តល់ជូនដល់អ្នក។ ត្រូវចងចាំថា អ្នកអាចទាក់ទងទៅកាន់ការិយាល័យរបស់គ្រូពេទ្យបាន ប្រសិនបើអ្នកមានសំណួរណាមួយ។

### អ្នកដឹងពីកូនរបស់អ្នកបានល្អជាងគេ

ប្រសិនបើគ្រូពេទ្យរបស់កូនអ្នកបានប្រាប់អ្នកឱ្យ "រង់ចាំមើលសិន" ប៉ុន្តែអ្នកមានអារម្មណ៍មិនស្រួលចំពោះការណែនាំនោះ៖

អ្នកអាចពិភាក្សាជាមួយនឹងអ្នកផ្សេងទៀតបាន (ដូចជាគ្រូពេទ្យ គ្រូបង្រៀន ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពម្នាក់ទៀត) ដើម្បីទទួលបានយោបល់ទីពីរ
**និង**
ទូរស័ព្ទសម្រាប់ការវាយតម្លៃដោយមិនគិតថ្លៃ ដើម្បីស្វែងយល់ថាតើកូនរបស់អ្នកអាចទទួលបានសេវាកម្មផ្សេងៗដែលអាចជាជំនួយ ដោយមិនគិតថ្លៃ ឬដោយចំណាយប្រាក់តិចបានឬទេ។

ប្រសិនបើកូនរបស់អ្នកមានអាយុក្រោម 3 ឆ្នាំ៖ ទូរស័ព្ទទៅកាន់កម្មវិធីអន្តរាគមន៍ Early Start នៃរដ្ឋរបស់អ្នក។ ស្វែករកលេខទូរស័ព្ទនៅលើគេហទំព័រ www.cdc.gov/FindEI

ប្រសិនបើកូនរបស់អ្នកមានអាយុចាប់ពី 3 ឆ្នាំឡើងទៅ៖
ទូរស័ព្ទទៅកាន់សាលារៀនកម្រិតបឋមសិក្សារបស់រដ្ឋនៅក្នុងតំបន់។

អ្នកមិនចាំបាច់ត្រូវការឱ្យមានការបញ្ជូនឈ្មោះរបស់គ្រូពេទ្យ ដើម្បីឱ្យកូនរបស់អ្នកទទួលការវាយតម្លៃសម្រាប់សេវាកម្មនានានោះឡើយ។

**សូមកុំរង់ចាំ។**
**ការធ្វើសកម្មភាពបានឆាប់រហ័ស អាចធ្វើឱ្យមានប្រយោជន៍យ៉ាងពិតប្រាកដ!**

**ទទួលបានការទំនាក់ទំនង៖** ទូរស័ព្ទទៅកាន់លេខ **833.903.3972** ឬចូលទៅកាន់គេហទំព័រ **HelpMeGrowLA.org** ឬក៏សាកសួរគ្រូពេទ្យរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។



HMGLA 109 3/2023 (Cambodian)

Help Me Grow is a collaboration between first 5 la Giving kids the best start and County of Los Angeles Public Health